ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខៈ ១០២៣ អយក/ប្រក

# ប្រកាស
# ស្តីពី
# ការកម្រិតវិន័យចំពោះបុគ្គលិកអប់រំក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/០៩៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០៨/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ
- បានឃើញអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ១២៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន
- បានឃើញអនុក្រឹត្យលេខ១០ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៧ ស្តីពីនីតិវិធីនៃការអនុវត្តវិន័យចំពោះមន្ត្រីរាជការស៊ីវិល



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ១៤៧ /២១៧ ២៥៣ /៤២៦ ៩៥១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០/ ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ : www.moeys.gov.kh

- បានឃើញប្រកាសលេខ២២៨០ អយក.ប្រក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១២ ស្តីពីនីតិវិធីនៃការស្នើ ឬការតវ៉ា ការប្តឹង និងដំណោះស្រាយសម្រាប់អ្នកសិក្សា មាតាបិតា ឬ អ្នកអាណាព្យាបាល និងបុគ្គលិកអប់រំ
- បានឃើញប្រកាសលេខ១១០ អយក.ប្រក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
- បានឃើញប្រកាសលេខ៩៨៣ អយក.ប្រក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តនូវកម្រងភារកិច្ចគណៈមេប្រយោគ និងគណៈកម្មការផ្សេងៗសម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
- តាមការចាំបាច់របស់ក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងកំណត់កម្រិតវិន័យចំពោះបុគ្គលិកអប់រំដែលប្រព្រឹត្តភាពមិនត្រឹមត្រូវក្នុងដំណើរការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។

**ប្រការ២.-**

ប្រកាសនេះមានគោលដៅ៖

- រក្សារបៀបរៀបរយក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
- ជំរុញឱ្យបុគ្គលិកអប់រំអនុវត្តអនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ច្បាប់ស្តីពីការអប់រំ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន
- ជំរុញការលុបបំបាត់អំពើអសកម្មនានាក្នុងដំណើរការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។

**ប្រការ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះបុគ្គលិកអប់រំដែលជាប់ពាក់ព័ន្ធនឹងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។

## ជំពូកទី២
## ភារកិច្ច និងកម្រិតវិន័យ

**ប្រការ៤.-**

បុគ្គលិកអប់រំដែលត្រូវបានចាត់តាំងឱ្យបំពេញភារកិច្ចជា ប្រធាន អនុប្រធាន និងសមាជិកនៃគណៈមេប្រយោគ គណៈកម្មការ ឬអនុគណៈកម្មការនានាក្នុងដំណើរការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ត្រូវទទួលខុសត្រូវក្នុងដំណើរការប្រឡងតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ៥.-**

ប្រធាន អនុប្រធាន និងសមាជិកនៃគណៈមេប្រយោគ គណៈកម្មការ ឬអនុគណៈកម្មការទាំងអស់ ត្រូវបំពេញកាតព្វកិច្ចធានារ៉ាប់រងសេវា គោរពម៉ោងធ្វើការ និងគោរពឋានានុក្រម បំពេញតួនាទីរបស់ខ្លួន ប្រកាន់យកភាពថ្លៃថ្នូរនិងមានកិត្តិយស គោរពការសម្ងាត់វិជ្ជាជីវៈ គិតគូរប្រយោជន៍ទូទៅ និងភក្ដីភាព និងកាតព្វកិច្ចអព្យាក្រឹតក្នុងការអនុវត្តការងារ និងភារកិច្ចដែលបានកំណត់ក្នុងប្រកាសលេខ៩៨៣ អយក.ប្រក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤ ស្ដីពីការដាក់ឱ្យអនុវត្តនូវកម្រងភារកិច្ចគណៈមេប្រយោគ និងគណៈកម្មការផ្សេងៗសម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។

**ប្រការ៦.-**

ប្រធាន អនុប្រធាន និងសមាជិកនៃគណៈមេប្រយោគ គណៈកម្មការ និងអនុគណៈកម្មការនានា ដែលប្រព្រឹត្តឱ្យមានកំហុសក្នុងដំណើរការប្រឡងត្រូវទទួលទណ្ឌកម្មខាងវិន័យដូចខាងក្រោម៖

ក. ទណ្ឌកម្មខាងវិន័យថ្នាក់ទី១៖

- ស្ដីបន្ទោស
- ស្ដីបន្ទោសដោយមានចំណារក្នុងសំណុំលិខិតផ្ទាល់ខ្លួន
- ផ្លាស់ដោយបង្ខំតាមវិធានការខាងវិន័យ
- លុបឈ្មោះចេញពីតារាងឡើងឋានន្តរស័ក្តិ ឬថ្នាក់។

ខ. ទណ្ឌកម្មខាងវិន័យថ្នាក់ទី២៖

- ស្ដីបន្ទោសជាទម្ងន់ បណ្ដាលឱ្យលុបឈ្មោះចេញពីតារាងឡើងឋានន្តរស័ក្តិ ឬថ្នាក់ បើសិនជាមានចុះឈ្មោះហើយ ឬធ្វើឱ្យយឺតក្នុងការដំឡើងឋានន្តរស័ក្តិ ឬថ្នាក់ក្នុងថេរវេលាមួយមានកំណត់ តែមិនត្រូវឱ្យលើសពី ២ឆ្នាំក្នុងការដំឡើងឋានន្តរស័ក្តិ ឬថ្នាក់តាមវេនជ្រើសរើស ឬតាមវេនអតីតភាព
- ដាក់ឱ្យនៅទំនេរគ្មានបៀវត្ស មិនឱ្យលើសពីមួយឆ្នាំ
- បន្ថយឋានន្តរសក្តិ ឬថ្នាក់មួយថ្នាក់ ឬច្រើនថ្នាក់
- ដាក់ឱ្យចូលនិវត្តន៍មុនកំណត់ ឬបញ្ឈប់ពីការងារដោយបង្ខំ
- បណ្ដេញចេញពីមុខតំណែងរាជការ។

**ប្រការ៧.-**

បុគ្គលិកអប់រំដែលបានប្រព្រឹត្តសកម្មភាពមិនត្រឹមត្រូវក្នុងការប្រឡងដូចខាងក្រោម ត្រូវទទួលទណ្ឌកម្មខាងវិន័យថ្នាក់ទី១ ដោយមិនទាន់គិតពីទោសតាមក្រមព្រហ្មទណ្ឌ៖

- ផ្ដល់ឬទទួលប្រាក់ដើម្បីរៀបចំបែងចែកតួនាទីក្នុងគណៈកម្មការនានាក្នុងដំណើរការប្រឡង
- អនុញ្ញាតឱ្យបេក្ខជនចម្លងកិច្ចការគ្នា
- អនុញ្ញាតឱ្យបេក្ខជនយកសំណៅឯកសារ និងឧបករណ៍អេឡិចត្រូនិចចូលក្នុងបន្ទប់ប្រឡង
- អនុញ្ញាតឱ្យបេក្ខជននិយាយឆ្លើយឆ្លងគ្នា ឬដើរពីតុមួយទៅតុមួយ

- យកសំណៅឯកសារពីអ្នកដទៃ ឬពីបេក្ខជនម្នាក់ទៅឱ្យបេក្ខជនម្នាក់ទៀតចម្លង
- ប្តូរប្លង់តុឱ្យបេក្ខជនខុសពីការកំណត់របស់គណៈមេប្រយោគ
- អនុញ្ញាតឱ្យសិស្សប្រើប្រាស់ឧបករណ៍អេឡិចត្រូនិចក្នុងបន្ទប់ប្រឡង
- ដាក់ពិន្ទុខុសប្រក្រតីក្នុងការកែសន្លឹកកិច្ចការបេក្ខជន
- អនុញ្ញាតឱ្យអ្នកដទៃប្រឡងជំនួសបេក្ខជន
- ជួយលាក់កំបាំងទង្វើមិនត្រឹមត្រូវរបស់បុគ្គលិកអប់រំផ្សេងទៀត
- បំពេញភារកិច្ចនានាតាមការកំណត់របស់ក្រសួងមិនបានពេញលេញ។

បុគ្គលិកអប់រំដែលបានប្រព្រឹត្តសកម្មភាពមិនត្រឹមត្រូវក្នុងការប្រឡងដូចខាងក្រោម ត្រូវទទួលទណ្ឌកម្មខាងវិន័យថ្នាក់ទី២ ដោយមិនទាន់គិតពីទោសតាមក្រមព្រហ្មទណ្ឌ៖

- ជួយធ្វើចម្លើយឱ្យបេក្ខជន និងធ្វើចរាចរចម្លើយពីបន្ទប់ប្រឡងមួយទៅបន្ទប់មួយទៀត
- ជួយបេក្ខជនដោយសហការគ្នាមើលផ្លូវគណៈគ្រប់គ្រង
- ផ្តល់សញ្ញាឱ្យសិស្ស ឬផ្តល់លេខសម្ងាត់ដល់អ្នកកែដើម្បីជាសញ្ញាសម្រាប់កែកិច្ចការ
- ធ្វើឱ្យបែកធ្លាយវិញ្ញាសា
- ប្តូរសន្លឹកកិច្ចការឱ្យបេក្ខជនក្រោយពេលប្រឡងរួច
- សរសេរបន្ថែមខ្លឹមសារលើសន្លឹកកិច្ចការបេក្ខជន
- បញ្ចុះបញ្ចូលបេក្ខជន ឬអ្នកអាណាព្យាបាលឱ្យសូកប៉ាន់ដើម្បីប្រឡងជាប់ ឬទទួលបាននិទ្ទេសល្អ
- បង្កើតបណ្តាញស្វែងរកផលកម្រៃពីការប្រឡង
- ទទួលប្រាក់ពីបេក្ខជនជាថ្នូរនឹងការចម្លង ឬធ្វើចម្លើយឱ្យបេក្ខជន
- គម្រាម ឬសម្លុតបេក្ខជនក្នុងពេលប្រឡង
- បង្កើតក្រុមធ្វើចម្លើយក្នុងពេលកំពុងដំណើរការប្រឡង
- ចូលរួម ឬឱ្យគេធ្វើគណៈកម្មការជំនួសបុគ្គលិកអប់រំទូទៅ។

## ជំពូកទី៣
## យន្តការ និងនីតិវិធីវាយតម្លៃ និងការដាក់វិន័យ

**ប្រការ៨.-**

យន្តការ និងនីតិវិធីវាយតម្លៃ និងការដាក់វិន័យត្រូវធ្វើឡើងភ្លាមបន្ទាប់ពីបញ្ចប់ដំណើរការការងារនៅតាមមណ្ឌលសំណេរ និងមណ្ឌលកំណែនីមួយៗ។

មណ្ឌលនីមួយៗត្រូវបង្កើតក្រុមប្រឹក្សាវិន័យសម្រាប់ដោះស្រាយភាពមិនប្រក្រតីដែលកើតឡើងនៅក្នុងមណ្ឌល។ ក្រុមប្រឹក្សាវិន័យរបស់មណ្ឌលត្រូវមានសមាសភាពដូចខាងក្រោម៖

- ប្រធានគណៈមេប្រយោគទូទាំងប្រទេសប្រចាំរាជធានី ខេត្ត ឬប្រចាំមណ្ឌល ប្រធាន
- ប្រធានគណៈកម្មការអប្បមាទទូទាំងប្រទេស អនុប្រធាន

- ប្រធានមណ្ឌល អនុប្រធាន
- អនុប្រធានមណ្ឌល សមាជិក
- អនុប្រធានគណៈកម្មការអប្បមាទ សមាជិក
- តំណាងគណៈកម្មការកណ្តាល ០១ រូប លេខាកត់ត្រា
- តំណាងគណៈកម្មការអនុរក្ស ឬតំណាងសមាជិកកំណៃ ឬតំណាងក្រុមមុខវិជ្ជា ឬតំណាងក្រុមបូកស្រង់ ០១ រូប សមាជិក។

ក្នុងករណីដោះស្រាយមិនដាច់ស្រេច ក្រុមប្រឹក្សាវិន័យតាមមណ្ឌលត្រូវបញ្ជូនសំណុំរឿងទៅក្រុមប្រឹក្សាវិន័យប្រចាំក្រសួង។ ចំពោះបុគ្គលដែលមិនពេញចិត្តនឹងដំណោះស្រាយរបស់ក្រុមប្រឹក្សាវិន័យតាមមណ្ឌល សាមីជនមានសិទ្ធិប្តឹងតវ៉ាមកក្រុមប្រឹក្សាវិន័យប្រចាំក្រសួង។

**ប្រការ៩.-**

ក្រសួងបង្កើតក្រុមប្រឹក្សាវិន័យសម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ប្រចាំក្រសួង ដើម្បីត្រួតពិនិត្យតាមដាន និងដោះស្រាយលើការដាក់វិន័យបុគ្គលិកអប់រំដែលប្រព្រឹត្តមិនត្រឹមត្រូវក្នុងដំណើរការប្រឡង និងរាល់ដំណោះស្រាយមិនដាច់ស្រេចរបស់ក្រុមប្រឹក្សាវិន័យតាមមណ្ឌល។

ការចាត់តាំងសមាសភាព នីតិវិធី និងយន្តការបំពេញការងាររបស់ក្រុមប្រឹក្សាវិន័យសម្រាប់ការប្រឡងប្រចាំក្រសួង ត្រូវកំណត់ដោយលិខិតបទដ្ឋានដោយឡែក។

**ប្រការ១០.-**

រាល់ការសម្រេចដាក់វិន័យរដ្ឋបាល ត្រូវធ្វើឡើងដោយផ្អែកលើឧបករណ៍វាយតម្លៃ របាយការណ៍ ឬកំណត់ហេតុ ច្បាប់ ប្រកាសលេខ៩៨៣ អយក.ប្រក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៨ ស្តីពីការដាក់ឱ្យអនុវត្តនូវកម្រងភារកិច្ចគណៈមេប្រយោគ និងគណៈកម្មការផ្សេងៗសម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ការសម្រេចដាក់កម្រិតវិន័យរដ្ឋបាលត្រូវអនុលោមតាមករណីនីមួយៗ តាមការប្រព្រឹត្តតាមកំហុស និងតាមព្យសនកម្ម។

**ប្រការ១១.-**

បេក្ខជន មាតាបិតា អ្នកអាណាព្យាបាល ឬអ្នកពាក់ព័ន្ធដែលមិនពេញចិត្តនឹងលទ្ធផលនៃការប្រឡង មានសិទ្ធិប្តឹង តវ៉ាក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃ ចាប់ពីថ្ងៃប្រកាសលទ្ធផលប្រឡង។ អ្នកប្តឹង តវ៉ាត្រូវសរសេរជាលាយលក្ខណ៍អក្សរត្រឹមត្រូវ មានភស្តុតាង មានឈ្មោះ មុខរបរ អាសយដ្ឋានច្បាស់លាស់ និងមានការទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

ក្នុងករណីមានពាក្យបណ្តឹង ឬពិនិត្យឃើញថា ការប្រឡងមានភាពមិនប្រក្រតីលើកិច្ចការរបស់បេក្ខជន និងលើការអនុវត្តភារកិច្ចរបស់គណៈមេប្រយោគ និងគណៈកម្មការផ្សេងៗ ក្រសួងត្រូវបង្កើតគណៈកម្មការកោសល្យវិច័យ។

គណៈកម្មការកោសល្យវិច័យ ត្រូវចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ក្នុងចំណោមគណៈមេប្រយោគទូទាំងប្រទេស បុគ្គលិកអប់រំដែលមានសមត្ថភាព និងសុចរិតភាព និងប្រធានគណៈកម្មការដែលពាក់ព័ន្ធនឹងភាពមិនប្រក្រតីនោះ។

## ជំពូកទី៤
## ទោសប្បញ្ញត្តិដែលមានចែងនៅក្នុងច្បាប់ជាធរមាន

**ប្រការ១២.-**

បទល្មើសការបន្លំក្នុងការប្រឡង តាមមាត្រា៤៩នៃច្បាប់ស្តីពីការអប់រំ ចែងថា សាមីខ្លួន ឬជនណាដែលប្រឡងជំនួស ឬបន្លំគ្រប់រូបភាពក្នុងការប្រឡងដូចបានបញ្ញត្តិក្នុងមាត្រា២៦ នៃច្បាប់នេះ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ពី ១.០០០.០០០ (មួយលាន)រៀល ទៅ ៥.០០០.០០០ (ប្រាំលាន)រៀល។

ករណីមិនរាងចាល សាមីខ្លួនត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ចំនួនទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍ខាងលើ ហើយត្រូវព្យួរការប្រឡងសម្រាប់រយៈពេល ២(ពីរ)ឆ្នាំ ឬហាមឃាត់មិនឱ្យចុះឈ្មោះក្នុងបញ្ជីប្រឡងជាស្ថាពរ។

ចំពោះជនដែលប្រឡងជំនួស ឬបន្លំគ្រប់រូបភាពក្នុងការប្រឡង ត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។

**ប្រការ១៣.-**

បទល្មើសពាក់ព័ន្ធនឹងដំណើរការនៃការប្រឡង តាមមាត្រា៥០នៃច្បាប់ស្តីពីការអប់រំចែងថា គ្រប់ទង្វើដែលប្រព្រឹត្តឡើងដោយបុគ្គលិកអប់រំមានភាពមិនត្រឹមត្រូវក្នុងដំណើរការនៃការប្រឡង ដូចបានបញ្ញត្តិក្នុងមាត្រា២៦នៃច្បាប់នេះ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ពី ២.០០០.០០០(ពីរលាន)រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល។ ចំពោះបុគ្គលិកអប់រំសាធារណៈត្រូវទទួលទណ្ឌកម្មខាងវិន័យថ្នាក់ទី១។

ក្នុងករណីមិនរាងចាល ត្រូវទទួលពិន័យអន្តរកាណ៍ជាប្រាក់ចំនួនទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍ខាងលើ។ ចំពោះបុគ្គលិកអប់រំសាធារណៈ ត្រូវទទួលទណ្ឌកម្មខាងវិន័យថ្នាក់ទី២បន្ថែមទៀត។ ចំពោះបុគ្គលិកអប់រំឯកជនត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤.-**

បទល្មើសពាក់ព័ន្ធនឹងការផ្តល់វិញ្ញាបនបត្រ ឬ សញ្ញាបត្រ តាមមាត្រា៤៨នៃច្បាប់ស្តីពីការអប់រំចែងថា គ្រប់ការផ្តល់វិញ្ញាបនបត្រឬសញ្ញាបត្រដែលមានភាពមិនត្រឹមត្រូវតាមបទប្បញ្ញត្តិនៃមាត្រា១៤នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ២.០០០.០០០ (ពីរលាន)រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន)រៀល និងដាក់ពន្ធនាគារពី ១ (មួយ)ឆ្នាំ ទៅ ៣ (បី)ឆ្នាំ។

**ប្រការ១៥.-**

បទប៉ះពាល់ដល់អាថ៌កំបាំងខាងវិជ្ជាជីវៈ តាមមាត្រា៣១៤នៃក្រមព្រហ្មទណ្ឌចែងថា បុគ្គលដែលកាន់កាប់ព័ត៌មានដែលមានលក្ខណៈអាថ៌កំបាំង ដោយមូលហេតុនៃស្ថានភាព មុខរបរ មុខងារ ឬ

បេសកកម្មរបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ប្រសិនបើបុគ្គលនោះបង្ហាញព័ត៌មាននេះ ដល់បុគ្គលដែលគ្មានសមត្ថកិច្ច ដើម្បីដឹងពីព័ត៌មាននេះ។

មិនមែនជាបទល្មើសទេ ក្នុងករណីដែលច្បាប់អនុញ្ញាត ឬតម្រូវឱ្យបង្ហាញអាថ៌កំបាំង។

**ប្រការ១៦.-**

បទរំលោភអំណាច តាមមាត្រា៣៥នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ចែងថា អំពើប្រព្រឹត្តដោយអ្នករាជការសាធារណៈ ឬដោយពលរដ្ឋដែលទទួលអាណត្តិសាធារណៈតាមការបោះឆ្នោត នៅក្នុងការបំពេញមុខងាររបស់ខ្លួន ឬក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ចាត់វិធានការរារាំងការអនុវត្តច្បាប់ ដើម្បីទទួលបានដោយខុសច្បាប់នូវអត្ថប្រយោជន៍ណាមួយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ) ឆ្នាំ ទៅ ៥(ប្រាំ) ឆ្នាំ និង ពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន)រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល។

បទល្មើសនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥(ប្រាំ)ឆ្នាំ ទៅ១០(ដប់)ឆ្នាំ ប្រសិនបើបទល្មើសនេះមានប្រសិទ្ធភាព។

**ប្រការ១៧.-**

បទស៊ីសំណូក តាមមាត្រា៥៩៤នៃក្រមព្រហ្មទណ្ឌ ចែងថា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ)ឆ្នាំ ទៅ១៥(ដប់ប្រាំ)ឆ្នាំ អំពើប្រព្រឹត្តដោយអ្នករាជការសាធារណៈ ឬដោយពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដែលទទូចសុំ ឬ យល់ព្រមទទួល ដោយគ្មានសិទ្ធិ ដោយផ្ទាល់ ឬដោយប្រយោលនូវអំណោយ ជំនូន ការសន្យា ឬ អត្ថប្រយោជន៍ណាមួយដើម្បី៖

១- បំពេញកិច្ចនៃមុខងាររបស់ខ្លួន ឬ កិច្ចដែលសម្រួលដោយមុខងាររបស់ខ្លួន។

២- មិនបំពេញកិច្ចនៃមុខងាររបស់ខ្លួន ឬ កិច្ចដែលសម្រួលដោយមុខងាររបស់ខ្លួន។

**ប្រការ១៨.-**

បទសូកប៉ាន់ តាមមាត្រា៦០៥នៃក្រមព្រហ្មទណ្ឌ ចែងថា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ៥(ប្រាំ)ឆ្នាំ ទៅ១០(ដប់)ឆ្នាំ បុគ្គលណា ដោយគ្មានសិទ្ធិដោយផ្ទាល់ ឬ ដោយប្រយោល ប្រគល់អំណោយ ឬ ជំនូន ធ្វើការសន្យាជាមួយ ឬ ផ្តល់អត្ថប្រយោជន៍អ្វីមួយដល់អ្នករាជការសាធារណៈ ឬ ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដើម្បីឱ្យអ្នករាជការ ឬ ពលរដ្ឋនោះ៖

១- បំពេញកិច្ចនៃមុខងាររបស់ខ្លួន ឬ កិច្ចដែលសម្រួលដោយសារមុខងាររបស់ខ្លួន។

២- មិនបំពេញកិច្ចនៃមុខងាររបស់ខ្លួន ឬ កិច្ចដែលសម្រួលដោយសារមុខងាររបស់ខ្លួន។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**ប្រការ១៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ២០.-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ប្រធាននាយកដ្ឋាននីតិកម្ម អធិការនៃអធិការដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ប្រធានការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ នាយក នាយិកាគ្រឹះស្ថានសិក្សា និងអង្គភាពពាក់ព័ន្ធត្រូវអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ១០ ឆ្នាំ២០១៨

បណ្ឌិត ហង់ ជួន ណារ៉ុន

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អង្គភាពប្រឆាំងអំពើពុករលួយ
- ខុទ្ទកាល័យក្រសួងអប់រំ យុវជន និងកីឡា
- អង្គភាពក្រោមឱវាទទីស្តីការក្រសួង
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត

«ដើម្បីជូនជ្រាប»

- ដូចប្រការ២០

«ដើម្បីអនុវត្ត»

- ឯកសារ-កាលប្បវត្តិ នា.នីតិកម្ម